**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត**
**កំពត**

**តាងនាមប្រជាពលរដ្ឋខ្មែរ**

**សំណុំរឿងព្រហ្មទណ្ឌលេខៈ ៧៦៨**
ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨
សំណុំរឿងស៊ើបសួរលេខ ៤៧០
ចុះថ្ងៃទ១០ ខែធ្នូ ឆ្នាំ២០១៨
សំណុំរឿងជំនុំជម្រះលេខ ៩២
ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩
**សាលក្រមព្រហ្មទណ្ឌលេខៈ ២៥១ "ខ"**
ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩

បានបើកសវនាការជាសាធារណៈនៅសាលសវនាការ នៃសាលាដំបូងខេត្តកំពត។
កាលបរិច្ឆេទបើកសវនាការថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ។
កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ក្រុមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូង ខេត្តកំពត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង ខេត្តកំពត

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៧៦៨ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

ក.ឈ្មោះ [redacted] ម៉ាន ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរសិស្សថ្នាក់ទី៨ កើតនៅភូមិ [redacted] ខេត្តកំពត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ផល្លី (រស់) ម្តាយឈ្មោះ [redacted] រ៉ាវី (ស្លាប់) នៅលីវ ជាអនីតិជន ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

ខ.ឈ្មោះ [redacted] វិចិត្ត ហៅចិត្ត ភេទប្រុស កើតឆ្នាំ២០០១ ជនជាតិខ្មែរ កើតនៅភូមិ [redacted] ខេត្តកំពត និងទីលំនៅបច្ចុប្បន្ននៅភូ [redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ទិត (រស់) ម្តាយឈ្មោះ [redacted] រុន (រស់) នៅលីវ ជានីតិជន ទោសពីមុន គ្មាន ។

គ.ឈ្មោះ [redacted] វិមាន ហៅមាន ភេទប្រុស កើតឆ្នាំ២០០០ ជនជាតិខ្មែរ កើតនៅ [redacted] ខេត្តកំពត និងទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] រិទ្ធី (រស់) ម្តាយឈ្មោះ [redacted] សុបិន (រស់) នៅលីវ ជានីតិជន ទោសពីមុន គ្មាន ។

Scanned with CamScanner

ឃ.ឈ្មោះ[redacted]កាន ភេទប្រុស កើតឆ្នាំ១៩៩៦ ជនជាតិខ្មែរ កើតនៅភូមិ[redacted] ខេត្តកំពត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពត ឪពុកឈ្មោះ[redacted] សុវណ្ណារ៉ា (រស់) ម្តាយឈ្មោះ [redacted] កន (រស់) នៅលីវ ជានីតិជន ទោសពីមុន គ្មាន ។

ង.ឈ្មោះ[redacted]សំណាង ភេទប្រុស កើតឆ្នាំ១៩៩៧ ជនជាតិខ្មែរ កើតនៅភូមិ[redacted] ខេត្តកំពត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពត ឪពុកឈ្មោះ[redacted]សារី (រស់) ម្តាយឈ្មោះ [redacted] មុំ (រស់) នៅលីវ ជានីតិជន ទោសពីមុន គ្មាន ។

ច.ឈ្មោះ[redacted]ច័ន្ទឌីណា ហៅឌីណា ភេទប្រុស កើតឆ្នាំ១៩៩៣ ជនជាតិខ្មែរ កើតនៅភូ[redacted] ខេត្តកំពត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពត ឪពុកឈ្មោះ[redacted]ឆុំ (រស់) នៅលីវ ជានីតិជន ទោសពីមុន គ្មាន ។

ឆ.ឈ្មោះ[redacted]ដួងតារារត្ន័ ហៅសល់ ភេទប្រុស កើតឆ្នាំ២០០៥ ជនជាតិខ្មែរ កើតនៅភូមិ[redacted] ខេត្តកំពត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពត ឪពុកឈ្មោះ[redacted] ដួងរស្មី , ម្តាយឈ្មោះ[redacted] រ៉ូប៉ា នៅលីវ ជាអនីតិជន ទោសពីមុន គ្មាន ។

ជ.ឈ្មោះ[redacted] ប៊ុនរ័ត្ន ហៅរ័ត្ន ភេទប្រុស កើតឆ្នាំ២០០០ ជនជាតិខ្មែរ កើតនៅភូមិ[redacted] ខេត្តកំពត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted]ប៊ុនលី (រស់) ម្តាយឈ្មោះ[redacted] ហេង (ស្លាប់) នៅលីវ ជានីតិជន ទោសពីមុន គ្មាន ។

ដោយមានលោក[redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ[redacted]ប៊ុនរ័ត្ន ហៅ រ័ត្ន និងសំណុំរឿងព្រហ្មទណ្ឌលេខ៧៦៨ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨ ទាំងមូល ។

ត្រូវបានចោទប្រកាន់ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិទី្វខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៨ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៥៦ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកំពត។

## ដើមបណ្តឹងរដ្ឋប្បវេណី

ឈ្មោះ [redacted]គីមសុង ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងកញ្ចែត ឃុំកំពង់សំរោង ស្រុកទឹកឈូ ខេត្តកំពត ។

## អង្គហេតុមានដូចតទៅ:

កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៨ ម៉ោងជាង១២យប់ ស្ថិតនៅចំណុចភូមិទី្វខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត មានឈ្មោះ[redacted] ម៉ាន និងបក្សពួកបាននាំ គ្នាដេញកាប់ជនរងគ្រោះឈ្មោះស៊ន គីមស៊ុង ភេទប្រុស អាយុ៣១ឆ្នាំ បណ្តាលឲ្យរបួស ។ ក្រោយមកនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨ ឈ្មោះ[redacted] ម៉ាន និងបក្សពួកក៏បាននាំគ្នាទៅវាយអ្នកដទៃ នៅចំណុចមុខភ្លោង ទ្វារសាលាព្រះរាជសម្ភារ ។ តាមចម្លើយរបស់ឈ្មោះ[redacted] ម៉ាន ដែលបានឆ្លើយចំពោះមុខសមត្ថកិច្ចនគរ

Scanned with CamScanner

បាល និងតំណាងអយ្យ ការបានឆ្លើយសារភាពថា ខ្លួននិងបក្សពួកពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។

## នាពេលសវនាការក្រោយពីបាន

-ស្តាប់ចម្លើយជនជាប់ចោទ

-ស្តាប់ចម្លើយដើមបណ្តឹង

-ស្តាប់សាក្សី

-ស្តាប់អំណានឯកសារបាយការណ៍ និងកំណត់ហេតុផ្សេងទៀតដែលមានក្នុងសំណុំរឿង

-ស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

១.កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨ ថា មានអំពើ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខក្លោងទ្វារសាលាព្រះរាជសម្ភារ ស្ថិតនៅភូមិអូរតូច សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត ។

២.តាមដីកាសន្និដ្ឋានស្ថាពរលេខ៧៦ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ របស់តំណាងអយ្យការ និងតាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ១៥៦ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរចោទប្រកាន់៖១ឈ្មោះ [redacted] ម៉ាន ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរឥស្លាម ២.ឈ្មោះ [redacted] វិចិត្ត ហៅចិត្ត ភេទប្រុស កើតឆ្នាំ២០០០ ជនជាតិខ្មែរ, ៣.ឈ្មោះ [redacted] មាន ហៅមាន ភេទប្រុស កើតឆ្នាំ២០០០ ,៤ឈ្មោះ [redacted] កាន ភេទប្រុស កើតឆ្នាំ១៩៩៦, ៥.ឈ្មោះ [redacted] ប៊ុនវ័ត្ន ហៅវ័ត្ន ភេទប្រុស កើតឆ្នាំ២០០០, ៦.ឈ្មោះ [redacted] សំណាង ភេទប្រុស កើតឆ្នាំ១៩៩៧, ៧.ឈ្មោះ [redacted] ដួងតារាវត្តី ហៅសល់ ភេទប្រុស កើតឆ្នាំ២០០៥ ,៨.ឈ្មោះ [redacted] ច័ន្ទឌីណា ភេទប្រុស កើតឆ្នាំ១៩៩៣ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិទីខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពី០២ ខែធ្នូ ឆ្នាំ២០១៨ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

៣.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ម៉ាន បានឆ្លើយនាពេលសវនាការថា ខ្លួនបានប្រ. ព្រឹត្តដូចការចោទប្រកាន់មែន ឈ្មោះសល់ បានហៅខ្លួនទៅមានគ្នា៣នាក់ ឈ្មោះចិត្ត និងខ្លួនទៅវាយនៅសាលាព្រះរាជសម្ភារ ពេលនោះគេនិយាយគ្នាថាទៅមើលគេវាយ មានឈ្មោះតាន់ ឈ្មោះឌីណា ឈ្មោះពៅ និងឈ្មោះរដ្ឋ វាយដៃ និង ដៃ ពេលនោះខ្លួនអង្គុយលើម៉ូតូមើលគេ ពេលឆ្លើយនៅចំពោះមុខតំណាងអយ្យការខ្លួនឆ្លើយថាខ្លួននៅទីនោះមែន ពេលនោះខ្លួនចេះតែឆ្លើយ ទៅដោយពេលគេវាយគ្នាមិនមានឈ្មោះប៊ុនវ័ត្នទេ ដោយពេលនោះខ្លួនច្រឡំឈ្មោះ ដោយពេលនោះខ្លួនភ័យពេក ខ្លួនបានវាយមួយកែងដៃ អាចឲ្យតុលាការពិចារណា ។

.តាមចម្លើយដើមបណ្តឹងឈ្មោះ [redacted] គីមសុង បានឆ្លើយនាពេលសវនាការថា ពេលពួកគេវាយនិងកាប់ខ្លួនគឺពេលយប់នៅម៉ោង១២យប់ជាង ចេញពីខ្ទឹបប្រាហ្លុននៅជិតសាលា១មករា មានដាវមានខ្សែក្រវាត់ ពេលវាយគ្នានៅសាលាព្រះរាជសម្ភារ ខ្លួនមិននៅទីនោះទេ ព្រោះខ្លួនត្រូវរបួសហើយខ្លួនឲ្យរកយុត្តិធម៌នៅប្រាហ្លុន នេះបញ្ជាក់ថាជនរងគ្រោះនៅឯសាលាព្រះរាជសម្ភារ និងមានឈ្មោះ [redacted] គីមសុង ទេនោះការទាមទាររបស់គាត់ តុលាការមិនពិចារណាទេ ។

.តាមចម្លើយសាក្សីឈ្មោះទាវ ឡាយឈុ បានឆ្លើយនាពេលសវនាការថា ពេលកើតហេតុខ្លួនដេកនៅផ្ទះរបស់ឈ្មោះ[redacted] ប៊ុនវ័ន្ត នៅម៉ោងប្រហែល ៩ទៅ១០យប់ ពេលព្រឹកឡើងខ្លួនដេកមិនទាន់ឡើងទេ ពេលងើបពីដេកនៅម៉ោងប្រហែល៩ជិតម៉ោង១០ព្រឹក ហើយឈ្មោះវ័ន្ត នៅដេក ខ្លួនស្គាល់យូរហើយដែរ ឈ្មោះប៊ុនវ័ន្ត មិនខូចទេ ឈ្មោះ[redacted]ម៉ាន ខ្លួនស្គាល់ ប្អូនរបស់ឈ្មោះប៊ុនវ័ន្ត ចេញពីសាលារៀននៅម៉ោងប្រហែល១១ព្រឹកប្រាប់ថា មានគេវាយគ្នានៅសាលាព្រះរាជសម្ភារ ពេលនោះឈ្មោះប៊ុនវ័ន្ត បានឡើងពីដេកហើយខ្លួនបានចេញទៅផឹកកាហ្វេជាមួយគ្នា អាចឲ្យតុលាការពិចារណាបាន ។

៤.តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ដើមបណ្តឹង និងសាក្សី នាពេលសវនាការរួចមកឃើញថា ជនជាប់ចោទឈ្មោះ[redacted]ម៉ាន សារភាពថាខ្លួនបានវាយគេត្រូវមួយកែង តែឈ្មោះ[redacted] ប៊ុនវ័ន្ត មិនបានចូលរួមទេ សុំឲ្យប្រធានក្រុមប្រឹក្សាសម្រេចតាមច្បាប់លើឈ្មោះ[redacted]ប៊ុនវ័ន្ត ចំណែកឈ្មោះ[redacted]ម៉ាន សារភាព ជនជាប់ចោទឈ្មោះ[redacted] វិចិត្ត ហៅចិត្ត, ឈ្មោះ[redacted]វិមាន ,ឈ្មោះ[redacted]កាន, ឈ្មោះ[redacted] សំណាង ,ឈ្មោះ[redacted]ដួងតារាវត្តី និងឈ្មោះឆ្វយ ច័ន្ទនីណា បានគេចខ្លួនពិតជាបានចូលរួមប្រព្រឹត្តបទល្មើស ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដូច្នេះតំណាងអយ្យការតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៧៦ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ទុកជាបានការដដែល តែតំណាងអាយ្យការសុំកែប្រែទីតាំង ប្រព្រឹត្តបទល្មើស និងថ្ងៃប្រព្រឹត្តបទល្មើស ប្រព្រឹត្តនៅចំណុចមុខច្លោងទ្វារសាលាព្រះរាជសម្ភារ ស្ថិតនៅភូមិអូរតូច សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨ វិញ ប្តឹងសុំឲ្យតុលាការសម្រេចតាមច្បាប់ឲ្យតុលាការពិចារណា ។

៥.លោក [redacted] មេធាវីបានធ្វើសេចក្តីសន្និដ្ឋាន ការពារជនជាប់ចោទឈ្មោះ[redacted] ប៊ុនវ័ន្ត ហៅ វ័ន្ត ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ[redacted]ម៉ាន ដើមបណ្តឹង និងសាក្សី ឃើញថា កូនក្តីខ្លួនមិនបានចូលរួមធ្វើសកម្មភាពវាយគ្នា នៅចំណុចមុខច្លោងទ្វារសាលាព្រះរាជសម្ភារ ស្ថិតនៅភូមិអូរតូច សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០ ១៩ នោះទេ ដោយពេលនោះកូនក្តីខ្លួនបានដេកនៅផ្ទះជាមួយសាក្សីឈ្មោះ[redacted] ឡាយឈុ លុះដល់ម៉ោងជិត១០ព្រឹកទើបងើបពីដេក ដល់ម៉ោង ១១ព្រឹក ប្អូនរបស់ឈ្មោះ[redacted] ប៊ុនវ័ន្ត ហៅ វ័ន្ត បានមកពីសាលាប្រាប់បងខ្លួនថា មុននេះមានគេវាយគ្នា នៅមុខសាលាព្រះរាជសម្ភារ ហើយកូនក្តីខ្លួន និងឈ្មោះ [redacted] ឡាយឈុ ក៏បានទៅផឹកកាហ្វេ ហេតុនេះហើយសុំឲ្យលោកប្រធានក្រុមប្រឹក្សាសម្រេចបញ្ឈប់ការចាប់ខ្លួនកូនក្តីខ្លួន និងសុំឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ អាចឲ្យតុលាការពិចារណាបាន ។

.លោក [redacted] មេធាវីបានធ្វើសេចក្តីសន្និដ្ឋាន ឈ្មោះ[redacted]ម៉ាន អនុញ្ញាតឲ្យខ្លួនការពារជនជាប់ចោទឈ្មោះ[redacted]ម៉ាន, ឈ្មោះ[redacted]វិចិត្ត ហៅចិត្ត,ឈ្មោះ[redacted]វិមាន ,ឈ្មោ[redacted] កាន, ឈ្មោះ[redacted] សំណាង , ឈ្មោះ[redacted] ដួងតារាវត្តី និងឈ្មោះ[redacted] ច័ន្ទនីណា ដោយឈ្មោះ[redacted]ម៉ាន នេះជាអនីតិជន ក្នុងរបាយការណ៍មិនមានឈ្មោះ[redacted] ប៊ុនវ័ន្ត ហៅវ័ន្តចូលរួមទេ ហើយនៅពេលសមត្ថកិច្ចសួរ គឺគាត់ភ័យ តែពេលសវនាការ គឺគាត់បានឆ្លើយពិត ហើយឈ្មោះ[redacted]ប៊ុនវ័ន្ត ហៅ

វ័ត្ត មិនបានចូលរួមទេ ដូចមេធាវី[redacted] សន្និដ្ឋានដែរ ។ ឈ្មោះ[redacted]ម៉ាន ទៅជាមួយគេដែរតែគាត់មិនបានកាប់គេទេ ឈ្មោះ[redacted] ម៉ាន សារភាពថាវាយ១ដៃប៉ុណ្ណោះ ថែមទាំងអាយុ១៨ឆ្នាំ ជាអនីតិជន ក្នុងរឿងនេះសុំឲ្យប្រធានក្រុមប្រឹក្សាពិចារណា ប្រព្រឹត្តនៅចំណុចមុខក្លោងទ្វារសាលាព្រះរាជសម្ភារ ស្ថិតនៅភូមិអូរតូច សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ គាត់បានវាយក្រវមួយកែង ហើយពុំមានរបូសស្នាមអ្វីទេ ហើយវាយដៃ និងដៃពុំមានអាវុធ ហើយអំពើនេះមិនត្រូវចោទតាមមាត្រា២១៨ ធ្ងន់ធ្ងរណាស់ សុំកែមកមាត្រា២១៧វិញ សុំបន្ធូរបន្ថយទោសចំពោះអនីតិជន ចំណែកជនជាប់ចោទឈ្មោះ[redacted] វិចិត្ត ហៅចិត្ត,ឈ្មោះ[redacted]វិមាន, ឈ្មោះ[redacted] កាន ,ឈ្មោះ[redacted] សំណាង និង ឈ្មោះ[redacted] ច័ន្ទឌីណា ជនជាប់ចោទទាំងនេះមិនបានមកឆ្លើយទេ ក៏សុំបន្ធូរបន្ថយទោសដែរ ។

៦.ជនជាប់ចោទឈ្មោះ[redacted] ម៉ាន បានបញ្ជាក់ថា ពេលធ្វើសកម្មភាពវាយគ្នានៅ ចំណុចមុខក្លោងទ្វារសាលាព្រះរាជសម្ភារ ស្ថិតនៅភូមិអូរតូច សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ ឈ្មោះ[redacted] ប៊ុនវ័ត្ត ហៅវ័ត្ត មិនបានចូលរួមវាយគេទេ ស៊ីចង្វាក់ទៅនឹងសាក្សីឈ្មោះទាវ ឡាយឈូ គប្បីតុលាការឲ្យរួចផុតពីបទចោទ ។

៧.ជនជាប់ចោទឈ្មោះ[redacted] ម៉ាន,ឈ្មោះ[redacted] វិចិត្រ,ឈ្មោះ[redacted]វិមាន,ឈ្មោះ[redacted] កាន, ឈ្មោះ[redacted] សំណាង,ឈ្មោះ[redacted] ច័ន្ទឌីណា និងឈ្មោះ[redacted] ដួងតារាវត្តី ពិតជាមានចេតនាប្រព្រឹត្តអំពើហិង្សាដោយមានចេតនាមែន ពេលប្រព្រឹត្តជនជាប់ចោទទាំងអស់ បានបបួលគ្នាជាក្រុមទៅវាយលើជនរងគ្រោះ ដោយមានស្មារតីគ្រប់គ្រាន់នៅពេលប្រព្រឹត្តបទល្មើស ។

៨.អំពើល្មើសរបស់ជនជាប់ចោទទាំង ៧នាក់ បានប្រព្រឹត្តមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២១៨នៃក្រមព្រហ្មទណ្ឌ ។

៩.គ្មានភស្តុតាង និងគ្មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted]ប៊ុនវ័ត្ត ហៅវ័ត្ត ភេទប្រុស កើតឆ្នាំ២០០០ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខក្លោងទ្វារសាលាព្រះរាជសម្ភារ ស្ថិតនៅភូមិអូរតូច សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០ ១៩ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

១០.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted]ម៉ាន ភេទប្រុស អាយុ១៨ឆ្នាំ,២.ឈ្មោះ[redacted] វិចិត្ត ហៅចិត្ត ភេទប្រុស កើតឆ្នាំ២០០០, ៣.ឈ្មោះ[redacted]វិមាន ហៅមាន ភេទប្រុស កើតឆ្នាំ២០០០, ៤.ឈ្មោះ[redacted] កាន ភេទប្រុស កើតឆ្នាំ១៩៩៦, ៥.ឈ្មោះ [redacted] សំណាង ភេទប្រុស កើតឆ្នាំ១៩៩៧, ៦.ឈ្មោះ[redacted] ដួងតារាវត្តី ហៅសល់ ភេទប្រុស កើតឆ្នាំ២០០៥ និង ៧.ឈ្មោះ[redacted] ច័ន្ទឌីណា ភេទប្រុស កើត ឆ្នាំ១៩៩៣ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខក្លោងទ្វារសាលាព្រះរាជសម្ភារ ស្ថិតនៅភូមិអូរតូច សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

១១.ជនជាប់ចោទឈ្មោះ[redacted]ម៉ាន ទើបតែអាយុ១៨ឆ្នាំ គប្បីតុលាការពិចារណាអំពីទណ្ឌកម្ម។

Scanned with CamScanner

១២.ចំពោះឈ្មោះ [redacted] ដួងតារាវត្តី ភេទប្រុស កើតឆ្នាំ២០០៥ ចំណែកថ្ងៃ ខែ ឆ្នាំ ប្រព្រឹត្ត ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨ អាយុទើបតែ១៣ឆ្នាំតែប៉ុណ្ណោះតាមមាត្រា៣៩នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការសម្រេចមិនផ្តន្ទាទោសឡើយ ។

១៣.ដើមបណ្តឹងឈ្មោះ [redacted] គឹមសុង មិនបានរងគ្រោះនៅចំណុចមុខភ្លោងទ្វារសាលាព្រះរាជសម្ភារ ស្ថិតនៅភូមិអូរតូច សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ ទេ តែឈ្មោះ [redacted] គឹមសុង បានរងគ្រោះចេញពីខ្លឹបប្រជាហ្គននៅជិតសាលា១មករា ស្ថិតនៅចំណុចភូមិទ្វីខាងជើង សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត សុំឲ្យតុលាការរកយុត្តិធម៌ តុលាការមិនលើកមកពិចារណាឡើយ ។

## ដូច្នេះសម្រេច

១.ក.ឲ្យឈ្មោះ [redacted] ប៊ុនវ័ត្ន ហៅវ័ត្ន ភេទប្រុស កើតឆ្នាំ២០០០ ជនជាតិខ្មែរ រួចផុតពីបទចោទ

បទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខភ្លោងទ្វារសាលាព្រះរាជសម្ភារ ស្ថិតនៅភូមិអូរតូច សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

ខ.ឈ្មោះ [redacted] ដួងតារាវត្តី ភេទប្រុស កើតឆ្នាំ២០០៥ មិនផ្តន្ទាទោសបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខភ្លោងទ្វារសាលាព្រះរាជសម្ភារ ស្ថិតនៅភូមិអូរតូច សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

២.ផ្តន្ទាទោស:

ក.ឈ្មោះ [redacted] ម៉ាន ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០៨ខែ (ប្រាំបីខែ) គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៨ ។

ខ.ឈ្មោះ [redacted] វិចិត្ត ហៅចិត្ត ភេទប្រុស កើតឆ្នាំ២០០១ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ(មួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន ។

គ.ឈ្មោះ [redacted] រិមាន ហៅមាន ភេទប្រុស កើតឆ្នាំ២០០០ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ (ពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន ។

ឃ.ឈ្មោះ [redacted] កាន ភេទប្រុស កើតឆ្នាំ១៩៩៦ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ (ពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន ។

ង.ឈ្មោះ [redacted] សំណាង ភេទប្រុស កើតឆ្នាំ១៩៩៧ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ (ពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន ។

ច.ឈ្មោះ [redacted] ច័ន្ទឌីណា ភេទប្រុស កើត ឆ្នាំ១៩៩៣ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ (ពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន ។

បទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខភ្លោងទ្វារសាលាព្រះរាជសម្ភារ ស្ថិតនៅភូមិអូរតូច សង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

៣.ក.រំលត់អានុភាពដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ១៤/១៩,លេខ១៥/១៩,លេខ១៦/១៩,លេខ១៧/១៩,លេខ១៨/១៩,លេខ១៩/១៩,លេខ២០/១៩ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ ។

Scanned with CamScanner

ខ.បង្គាប់ឲ្យចាប់ខ្លួនដូចខាងក្រោម:

. ឈ្មោះ [redacted] វិចិត្ត ហៅចិត្ត ភេទប្រុស កើតឆ្នាំ២០០១ ជនជាតិខ្មែរ

. ឈ្មោះ [redacted] វិមាន ហៅមាន ភេទប្រុស កើតឆ្នាំ២០០០ ជនជាតិខ្មែរ

. ឈ្មោះ [redacted] កាន ភេទប្រុស កើតឆ្នាំ១៩៩៦ ជនជាតិខ្មែរ

. ឈ្មោះ [redacted] សំណាង ភេទប្រុស កើតឆ្នាំ១៩៩៧ ជនជាតិខ្មែរ

. ឈ្មោះ [redacted] ច័ន្ទឌីណា ភេទប្រុស កើត ឆ្នាំ១៩៩៣ ជនជាតិខ្មែរ

៨.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ម៉ាន និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] វិចិត្ត ហៅចិត្ត, ឈ្មោះ [redacted] វិមាន ហៅមាន,ឈ្មោះ [redacted] កាន,ឈ្មោះ [redacted] សំណាង,ឈ្មោះ [redacted] ច័ន្ទឌីណា,ឈ្មោះ [redacted] ដួងតារាវត្តី ហៅសល់,ឈ្មោះ [redacted] ប៊ុនរ័ត្ន ហៅរ័ត្ន និងចំពោះមុខដើមបណ្ដឹងឈ្មោះ [redacted] គីមសុង ទុកពេលប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ក្រុមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

---

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១៤រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

កំពត,ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner